


# ឧបករណ៍សម្ងួតស្រូវដោយចង្ក្រានដុតអង្កាម

## ១. ហេតុអ្វីអង្កាមត្រូវបានប្រើប្រាស់សម្រាប់ចង្ក្រានម៉ាស៊ីនសម្ងួត ?



អង្កាមធ្វើអោយតម្លៃនៃការសម្ងួតស្រូវមានតម្លៃទាបដូច្នេះ ធ្វើអោយមានការប្រកួតប្រជែងជាមួយម៉ាស៊ីនសម្ងួតដែលប្រើប្រាស់ ប្រភពថាមពលផ្សេងៗ ដុតកម្តៅខ្យល់។ អង្កាមគឺជាកាកសំណល់ ដែលសល់ពីការកិនស្រូវ ដូចនេះតម្លៃរបស់វាគឺទាប រឺដូចតម្លៃដឹក ជញ្ជូនយកទៅដុតសម្ងួត។ នៅក្នុងប្រទេសវៀតណាម អង្កាមចំនួន ២,៥គីឡូក្រាម អាចផ្តល់កំដៅស្មើនឹងធ្យូង ដែលមានគុណភាពល្អ ១គីឡូក្រាម ប៉ុន្តែអង្កាមទម្ងន់ ២,៥គីឡូក្រាម នោះមានតម្លៃត្រឹមតែ១/៧ នៃតម្លៃធ្យូង១គីឡូក្រាម ប៉ុណ្ណោះ។ ដោយឡែកនៅប្រទេសកម្ពុជាអង្កាមមួយបាវទម្ងន់ ២០ ទៅ ៣០គីឡូក្រាម តម្លៃ ៣០០ ទៅ ៥០០រៀល ។

## ២. ប្រភេទមួយចំនួននៃចង្ក្រានដុតអង្កាម

ចង្ក្រានដុតអង្កាមមានពីរប្រភេទដែលផលិតឡើង ដូចបានបង្ហាញខាងក្រោម: កន្លែងចាក់អង្កាមរបស់ម៉ាស៊ីនទាំងពីរ មានទម្រេតបញ្ឆិត ដែលផ្តល់ភាពងាយស្រួលដល់ការចាក់អង្កាមចូល។ ចង្ក្រានដែលមានរាងជាប្រអប់ (The box-type) មិនមានគុណភាពល្អដូចចង្ក្រានដែលមានកន្លែងដុតជាស៊ីឡាំងទេ។



គំនូសបំព្រួញឡដុតអង្កាម មិនបន្សុទ្ធខ្យល់




គំនូសបំព្រួញឡដុតអង្កាមដែលខ្យល់ក្តៅត្រូវឆ្លងកាត់បំពង់បន្សុទ្ធខ្យល់

នាពេលថ្មីៗនេះ ដោយមានកិច្ចសហប្រតិបត្តិការរវាង វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) និង NLU បានបង្កើតម៉ាស៊ីនសម្ងួតប្រភេទម្យ៉ាងគឺ The Hohenheim ជាចង្ក្រានដែលមានលក្ខណៈស្វ័យប្រវត្តិ ហើយអាចដាក់អង្កាមដុតក្នុងមួយម៉ោងម្តង។ ការដុតអង្កាមមានលក្ខណៈសព្វល្អ និងអាចរក្សាសីតុណ្ហភាពពេលសម្ងួតអោយមានលំនឹង។ ចង្ក្រានអាចចាប់ភ្ជាប់ទៅនឹងម៉ាស៊ីនសម្ងួតប្រភេទ SHG-4 ជាម៉ាស៊ីនដែលមានសមត្ថភាពសម្ងួតម្តងបាន៤តោន។

## ៣. សមាសភាពរបស់ឡសម្ងួត

**១-ធុងរាងជីឡាវ** សម្រាប់ចាក់អង្កាមចូល

**២-ដែកសន្លឹក** ប្រើជាជំនួយជាទំរស្រទាប់អង្កាមនៅពេលដុត

**៣-បន្ទប់ចំហេះដំបូង** ប្រើដើម្បីដុតធ្វើឱ្យអស់ជាតិកាបូនពីសំបកអង្កាម

**៤-បន្ទប់ចំហេះបន្ទាប់** ប្រើដើម្បីដុតយកចំហេះក្នុងការសម្ងួត (បញ្ចេញផ្សែង) បានពីការដុតអង្កាម និង

**៥-រណ្តៅផេះ** ប្រើដើម្បីស្តុកផេះដែលបានពីការដុតរួច

## ៤. ការចាប់ផ្តើមបញ្ឆេះចង្ក្រានដុតអង្កាម



ដំបូងយើងត្រូវដាក់អង្កាមថ្នាក់ៗ នៅលើស្រទាប់ដែកសន្លឹករបស់ចង្ក្រាន។ បិទរនាំងការពារនៅពេលដាក់អង្កាមរួច។ កង្ហារនៃម៉ាស៊ីនសម្ងួតមិនទាន់ដំណើរការ យើងត្រូវប្រើកំទេចឈើ ឬក្រដាសដើម្បីដុតអង្កាមនៅលើដែកសន្លឹក។ នៅពេលអង្កាមបានឆេះឡើងចេញជាអណ្តាតភ្លើងហើយ យើងចាប់ផ្តើមបើកកង្ហារឡើង ហើយបើករនាំងដើម្បីផ្តល់កម្តៅ។ ដោយធ្វើការកំណត់ពេលវេលា (ប្រហែលជា ៥នាទី) ត្រួតពិនិត្យមើលថា បើសិនជាអង្កាមហូរឥតឈប់នោះ យើងត្រូវកាយផេះចេញជៀសវាងការស្ទះ។ ចង្ក្រានគួរតែដុតមិនអោយមានផ្សែង ហុយនាំផេះឡើងទៅជាមួយល្បាយខ្យល់សម្ងួតឡើយ។

## ៥. ការកត់ចំណាំពីសុវត្ថិភាព

- ទីតាំងដាក់ចង្ក្រានត្រូវតែស្ថិតនៅចំកន្លែងដែលមានខ្យល់បក់ចេញចូលគ្រប់គ្រាន់។
- ការពារកន្លែងដែលនៅជុំវិញចង្ក្រានកុំឱ្យមានសំរាម ឬវត្ថុអ្វីដែលអាចងាយឆាបឆេះ។
- វត្ថុដែលអាចឆេះបានងាយបង្កអោយមានភាពគ្រោះថ្នាក់ដូចជា ប្រេងសាំង គួរតែដាក់អោយឆ្ងាយពីចង្ក្រាន យ៉ាងហោចណាស់ ៦ម៉ែត្រ។

សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យវិស្វកម្មកសិកម្ម មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ០១ ភ្នំពេញ, ទូរស័ព្ទលេខ:(៨៥៥-២៣)២១៩ ៦៩៣-៤

ទូរសារលេខ (៨៥៥-២៣) ២១៩ ៨០០ | ទូរអក្សរ: cardi@cardi.org.kh | វែបសាយ: www.cardi.org.kh

Sbunna@cardi.org.kh | TRIN@cardi.org.kh | HUNYADANA@cardi.org.kh